តមកពីទំព័រទី ១ ២

ក្នុងគុកនេះ គេមានធ្វើបាបដែរឬទេនោះ.លោកទឹម សាខន បានសើចហើយនិយាយខ្លាំងៗថាវៀតណាមមិនដែលធ្វើបាប ខ្លួនប្រាណគាត់ទេ. មានតែខ្មែរទេដែលវាយគាត់សន្លប់ក្រោយពេលចាប់ផ្សឹកកាលឆ្នាំទៅ ។

តើពេលចេញពីពន្ធនាគារ នឹងត្រឡប់មកភ្នំដិនវិញដែរឬអត់ ? លោកទឹម សាខន ឆ្លើយផុយថា មិនមកទេ ខ្លាចខ្មែរធ្វើបាប. សុខចិត្តនៅហ្វៀង(កម្ពុជាក្រោម) ហើយ ពីព្រោះនៅទីនេះមានសុវត្ថិភាពជាងនៅកម្ពុជា ។ប្រភពបានឱ្យដឹងទៀតថាក្នុងរយៈពេលទៅចូលសួរសុខទុក្ខលោកទឹមសាខន នៅពន្ធនាគារ២ដងកាលពីខែមុន ដោយនៅពេលសួរសុខទុក្ខម្តងៗមានឆ្មាំគុកយួនអង្គុយក្បែរជានិច្ចនោះ លោកទឹម សាខនជូនសើចជូនយំថ្កោលទោសថាខ្មែរធ្វើបាបគាត់ វាយជំច្រំធាក់គាត់ស្ទើរងាប់ស្ទើររស់. ឯខាងវៀតណាមវិញ គេមិនបានប៉ះពាល់ដល់រាងកាយគាត់ទេ.វៀតណាមយកចិត្តទុកដាក់សុខភាពរបស់គាត់ណាស់ដែលហេតុនេះហើយ ក្រោយចេញពីមន្ទីរឃុំឃាំង លោកនឹងមិនមកនៅភ្នំដិនទៀតទេ ។

ឪពុក និងបងប្អូនបង្កើតរបស់លោកទឹម សាខន ទាំងអស់គ្នាបច្ចុប្បន្នរស់នៅភូមិភ្នំដិន ឃុំផ្សារ ស្រុកគិរីវង់ ខេត្តតាកែវ ។ នៅឯខេត្តមាត់ជ្រូក ពុំមានបងប្អូនសាច់សាលោហិតលោកទឹម សាខនរស់នៅទេ ។

ប្រភពដែលបានជួបលោកទឹម សាខននៅនឹងគុកយួនបានអោយដឹងទៀតថា សុខភាពរបស់លោកទឹម សាខនទ្រុឌទ្រោមខ្លាំង ។ លោកស្គាំងស្គម ដែលតាមដឹងគឺស្រកទម្ងន់ដល់ទៅជាង១០គ.ក. ហើយអ្វី ដែលជាការព្រួយបារម្ភនោះគឺអាកប្បកិរិយារបស់លោកមិននៅភាពប្រក្រតីដូចមុនទេ ។

អតីត អ្នកទោសនយោបាយខ្មែរនៅយួនស្ទើរតែទាំងអស់ច្រើនតែមានអារម្មណ៍ មិនប្រក្រតីនៅក្រោយពេលចេញពីពន្ធនាគារ ។ អតីតអ្នកគុកនយោបាយខ្លះបានឱ្យដឹងថា នៅពេលសួរចម្លើយម្តងៗពួកយួនបានធ្វើទារុណកម្ម ដូចជាការឆក់ខ្សែភ្លើងការបង្អត់អាហារបង្អត់ទឹក... ហើយនៅពេលសុខភាពអ្នកទោសទ្រុឌទ្រោម យួនតែងយកពេទ្យមកចាក់ថ្នាំ ដែលគេមិនដឹងថា ពេទ្យយួនចាក់ថ្នាំអ្វីទេ ។ អ្វីដែលគួរឱ្យកត់សំគាល់នោះ គឺក្រោយចេញពីមន្ទីរឃុំឃាំងយួន អ្នកណាៗក៏ផ្លាស់ប្តូរឥរិយាបទទាំងអស់ខ្លះទៀត ឈឺរ៉ាំរ៉ៃពិកលពិការ រហូតមួយជីវិតក៏មាន ។

សាក្សីរស់មួយចំនួនដែលធ្លាប់ជាប់គុកយួន បានឱ្យដឹងថា យួនតែងចាប់ខ្មែរ យកទៅដាក់គុកងងឹត ហើយនៅពេលសួរចម្លើយម្តងៗ គេមិនឱ្យឃើញមុខអ្នកសួរចម្លើយទេ តែគេធ្វើទារុណកម្មច្រើនបែបច្រើនយ៉ាង ដែលមិនអាចពណ៌នាអស់ទេ ។

លោកទឹម សាខនហាក់ដូចជាកំពុងធ្លាក់ក្នុងរបត់ចាស់នៃអតីតអ្នកទោសនយោបាយខ្មែររាប់រយនាក់មុនៗដែរនោះគឺអាកប្បកិរិយានិងសតិអារម្មណ៍លែងប្រក្រតីដូចដើម ដែលក្រុមអតីតអ្នកទោសនយោបាយ នៅស្រុកយួនខ្លះបាននិយាយថាវាទំនងណាស់ថាលោកទឹម សាខនអាចត្រូវអាជ្ញាធរពន្ធនាគារយួនចាក់ថ្នាំដែរហើយ ។ ទោះយ៉ាងណា ប្រភពមួយបាននិយាយថា នៅស្រុកយួនសព្វថ្ងៃមានអង្គការមួយ ជំនាញខាងការពារអ្នកទោសដែរ ដែលបើសិនជាអាជ្ញាធរពន្ធនាគារយួនចាក់ថ្នាំអ្វីដល់លោកទឹម សាខននោះច្បាស់ជាត្រូវអង្គការនេះពិនិត្យដឹងនៅពេលក្រោយជាមិនខាន ។ ទោះយ៉ាងណាប្រភពមិនអោយបញ្ចេញអត្តសញ្ញាណនេះ បានសារភាពថា ពីដើម(បួនដប់ឆ្នាំមុន) អាជ្ញាធរយួន បានចាក់ថ្នាំអ្នកទោសឱ្យឆ្កួត វិកលវិការតាមទំនើងមែន ប៉ុន្តែសព្វថ្ងៃអាជ្ញាធរយួនទំនងជា មិនប្រព្រឹត្តសកម្មភាពអមនុស្សធម៌ ដ៏មហាឧក្រិដ្ឋបែបនេះទៀតទេ ។

លោកទឹម សាខន ត្រូវអាជ្ញាធរយួនកាត់ទោសអោយជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ កាលពីខែកញ្ញាឆ្នាំទៅ គិតចាប់ពីថ្ងៃត្រូវចាប់ខ្លួន នៅថ្ងៃទី៣១ មិថុនាឆ្នាំ២០០៧ ។ ដូច្នេះអាជ្ញាយុកាលនៃសាលក្រមតុលាការយួននេះ លោកទឹម សាខន អាចនឹងត្រូវដោះលែង អោយមានសេរីភាពនៅរយៈពេល ២ទៅ៣ខែទៀតនេះ ៕